**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

ក្នុងស្មារតីបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងម៉ាឡេស៊ីលើវិស័យការងារ និងអភិវឌ្ឍន៍ធនធានមនុស្ស ជាពិសេសការការពារអត្ថប្រយោជន៍របស់ពលករ កម្មករនិយោជិតដែលឆ្លងដែនធ្វើការទៅវិញទៅមករវាងប្រទេសទាំងពីរនោះ ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំគណៈប្រតិភូកម្ពុជាទៅទស្សនកិច្ច និងជួបប្រជុំពិភាក្សាការងារជាមួយសមភាគីរបស់ខ្លួន ដែលដឹកនាំដោយឯកឧត្តម Dato Sri Richard Riot Anak Jaem រដ្ឋមន្ត្រីក្រសួងធនធានមនុស្សនៃម៉ាឡេស៊ីចាប់ពីថ្ងៃទី០៩ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។

នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ ដែលជាថ្ងៃទីពីរនៃដំណើរទស្សនកិច្ច ឯកឧត្តម **អ៊ិត សំហេង** និងឯកឧត្តម Dato Sri Richard Riot Anak Jaem បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ចំនួនពីរៈ

១. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការប្រើប្រាស់កំលាំងពលកម្ម
២. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការជ្រើសរើសនិងដាក់ឱ្យពលករខ្មែរធ្វើការតាមផ្ទះ

MOUទាំងពីរនេះ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់ការពារសិទ្ធិនិងផលប្រយោជន៍របស់ពលករ កម្មករ និងនិយោជិតនៃប្រទេសទាំងពីរ ទាំងនៅក្នុងដំណាក់កាលជ្រើសរើស ធ្វើការ និងមាតុភូមិនិវត្តន៍ត្រឡប់មកប្រទេសកំណើតរៀងខ្លួនវិញ។ អនុស្សរណៈនៃការយោគយល់នេះ ក៏នឹងជួយលើកកម្ពស់កិច្ចសហប្រតិបត្តិការលើវិស័យការងាររវាងប្រទេសទាំងពីរ ស្របតាមក្របខ័ណ្ឌសមាហរណកម្មសហគមសេដ្ឋកិច្ចអាស៊ានផងដែរ។

នៅក្នុងជំនួបពិភាក្សាការងារភាគីទាំងពីរក៏បានឯកភាពគ្នាៈ

១. ជម្រុញមន្ត្រីជំនាញនៃប្រទេសទាំងពីរជួបប្រជុំពិភាក្សាគ្នាឱ្យបានឆាប់ ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្ត MOU ទាំងពីរនេះ
២. បង្កើតប្រព័ន្ធគ្រប់គ្រងពលករ កម្មករនិយោជិត តាមប្រព័ន្ធអេឡិត្រូនិច
៣. ធ្វើបច្ចុប្បន្នភាពពលករកម្ពុជានៅម៉ាឡេស៊ី
៤. ភាគីម៉ាឡេស៊ីនឹងជួយសម្រួលក្នុងការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលមិនទាន់ស្របច្បាប់
៥. បង្កើនកិច្ចសហប្រតិបត្តិការលើវិស័យបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក
៦. ចាត់វិធានការទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម
៧. ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធនមនុស្សនៃម៉ាឡេស៊ី នឹងបំពេញទស្សនៈកិច្ចជាផ្លូវនៅកម្ពុជានាឆ្នាំ២០១៦ ខាងមុខ តាមការអញ្ជើញរបស់ភាគីកម្ពុជា។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារៈ(០២៣)៨៨ ២៧ ៦៩